# គោលបំណងនៃព្រឹត្តិការណ៍១៨មិនា១៩៧០

## The Eighteen March Design

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី១១ មិថុនា ២០០៥

ប្រវត្តិសាស្ត្រនិងចំបាំងរាំងជល់ មិនមែនកើតឡើងដោយចៃដន្យ, ដោយសារការហោងស៊យ, ដោយសារអយុត្តិធម៌នៃព្រហ្មលិខិត ឬក៏ដោយសារគោលនំណាងរបស់ព្រះជាម្ចាស់ឡើយ, ប្រវត្តិសាស្ត្រតែងកើតឡើងដោយសារឆន្ទៈរបស់មនុស្ស ។

ឧក្រិដ្ឋកម្មនៃថ្ងៃ «១៨មិនា១៩៧០» មិនមែនត្រូវបង្កើតឡើង ដោយសារតែជនជាតិខ្មែរនោះទេ... ពីព្រោះប្រជាជាតិខ្មែរដែលត្រូវរមៀលធ្លាក់ចូលក្នុងសង្គ្រាមហិនហោចអណ្តូរកប្ប ដែលមិនមែនជាសង្គ្រាមរបស់ខ្លួន មិនបានទទួលភាគចំណេញពីព្រឹត្តិការណ៍នេះឡើយ ។ នៅគ្រប់ឧក្រិដ្ឋកម្មទាំងអស់នៅលើភពផែនដីនេះ គឺអ្នកដែលបានទទួលភាគចំណេញនោះហើយ ដែលជាអ្នកបានធ្វើ ។ គោលបំណងនៃ «ព្រឹត្តិការណ៍១៨មិនា១៩៧០»... គឺជាការលេបទឹកដីកម្ពុជា ពីសំណាក់វៀតណាមខាងជើង និងពួកយៀកកុង, (ដូច្នេះយួនជាអ្នកចំណេញ គឺយួនជាអ្នកធ្វើ !), មិនមែនជាគោលបំណងរបស់ទេព្តាឬព្រះឥន្ទឯណាទេ... ពីព្រោះគ្រាន់តែ «ព្រឹត្តិការណ៍»នេះកើតឡើងភ្លាមកាលណា ពួកទ័ពយួនខាងជើង ដែលធ្លាប់តែសម្ងំនៅឯព្រំប្រទល់ ក៏ស្រាប់តែរត់ប្រសេចប្រសាច ចូលមកក្នុងដែនដីកម្ពុជា (ដូចកងទ័ពម៉ុងគោ្គលសំរុកចូលប្រទេសចិនអឺចឹងឯង) ដើម្បីវាយប្រហារបំបាក់កងទ័ពរបស់ឧត្តមសេនិយ លន់-នល់ ។

ខ្ញុំបានធ្វើការស្រាវជ្រាវអំពីប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ចំនួន៣០ឆ្នាំមកហើយ...តាំងតែពីប្រទេសបារាំង (ដែលខ្ញុំបានសំណាក់នៅ១០ឆ្នាំ) រហូតមកដល់សហរដ្ឋអាមេរិក, ខ្ញុំបានសង្កេតឃើញថា រាល់ពេលណាដែលមានកើត«ឧប្បត្តិហេតុខ្មែរកាប់សម្លាប់យួន» នៅសម័យបុរាណកាល គឺស្តេចយួនតែងតែបានរឹបអូសយកខេត្តខ្មែរនៅកម្ពុជាក្រោម បានមួយឬពីរជានិច្ចជាកាល ។ ដូច្នេះ«ឧប្បត្តិហេតុនៃការកាប់សម្លាប់យួន»គឺយួនជាអ្នកបានរៀបចំធ្វើ មិនមែនជាខ្មែរទេ ពីព្រោះជនជាតិខ្មែរទាំងអស់គ្នាជាអ្នកបាត់បង់ខាតនៅក្នុងប្រការនេះ ។

«នៅក្នុងឆ្នាំ១៧៣០, ក្រោមការញុះញង់របស់ជនជាតិលាវឆ្កួតម្នាក់, ពួកខ្មែរដែលហាក់ដូចជាត្រូវអារក្សជាន់ (ខ្មោចចូល) បានដើរកាប់សម្លាប់យួន ដែលពួកគេបានជួបប្រទះនៅភូមិភាគខាងត្បូងនៃព្រះរាជាណាចក្រ (កម្ពុជាក្រោម) ។

«ព្រះសត្ថាទី២ ក៏បានបញ្ជូនព្រះរាជស្តួងការ ដើម្បីទៅកំចាត់ពួកខ្មែរពុលក្តួចខ្មោចចូលអស់ទាំងនេះ ។ ព្រះចៅក្រុងវ៉េក៏បានឆ្លៀតឱកាសពេលនោះ ពង្រីកទឹកដីរបស់ខ្លួនមួយរំពេជ ។ ដោយយកលេសថា មកជួយរៀបចំឲ្យមានសណ្តាប់ធ្នាប់, ស្តេចអណ្ណាមក៏បញ្ជូនកងទ័ពមកវាយប្រហារខ្មែររហូតដល់ក្រុងភ្នំពេញ ។ បន្ទាប់ពីបានជួបប្រទះនឹងភ័ព្វវាសនាក្រឡាប់ចុះឡើងនៃសង្គ្រាម, ព្រះសត្ថាទី២, ដែលបានបោះបង់ចោលព្រះរាជធានីរបស់ទ្រង់ ដោយរត់ទៅពួននៅភ្នំសន្ទុក, ក៏ទទួលយល់ព្រមតាមការទាមទាររបស់ស្តេចអណ្ណាម ដែលធ្លាប់ជាអ្នកការពារទ្រង់, ហើយក៏ប្រគល់ខេត្តថ្មីពីរនៅដែនដីកូសាំងស៊ីនទៅឲ្យយួន គឺខេត្តមេ-សនិងលង់ហោរ ដែលប្រែឈ្មោះជាវៀតណាមថា មី-ថ និង វិញឡុង (គ.ស.១៧-៣១) » (ដកស្រង់ចេញពី Histoire du Cambodge- La peau de chagrin- par A. Dauphin - Meunier - Presses Universitaires de France - Paris 1968 - page 85) ។

⌘

⌘ ⌘

«សញ្ញាពិត» និង «សញ្ញាឃើញ» ៖

បើនិយាយតាមក្បួនយុទ្ធសាស្ត្រចិន, សញ្ញាដែលគេមើលឃើញ មិនមែនជាសញ្ញាពិតទេ, ចំណែកសញ្ញាពិត គេមើលមិនឃើញទាល់តែសោះ ។ ជាឧទាហរណ៍ ទាក់ទងនឹងព្រឹត្តិការណ៍១៨មិនា១៩៧០...

«សញ្ញាឃើញ»ទី១ ៖ នរណាៗក៏បានមើលឃើញដែរថា លោកឧត្តមសេនិយលន់-នល់បានទម្លាក់សម្តេចសីហនុ ។ ក៏ប៉ុន្តែតាមសេចក្តីពិត, ស្តេចអង្គនេះបានរត់ចូលខ្លាំងដោយអង្គឯងសោះ តាំងពីថ្ងៃ៦មករា១៩-៦៩ម្ល៉េះ ។ ស្តេចសីហនុជាខ្មែរវង្វេងជាតិ, ជាសត្វក្រពើវង្វេងបឹង, ជាស្តេចវង្វេងទ័ព ។ ស្តេចសីហនុមិនមែនជាស្តេចខ្មែរទេ... គឺជាស្តេចយៀកកុង ! ហេតុអ្វីបានជាដូច្នេះទៅវិញ ? ពីព្រោះគាត់ជាអាយ៉ងដាច់ថ្លៃរបស់យួន, ជាតុក្កតាបញ្ចូលរូបសុទ្ធសាធ ដែលធ្វើអ្វីៗ ឬស្តីថាអ្វីៗ តាមតែវៀតណាមបង្គាប់បញ្ជាទាំងអស់ (ដូចជាជនជាតិលាវឆ្កួតនៅខាងលើ, ស្តេចសីហនុជាស្តេចឆ្កួតដែលទោះជាញុះញង់ឲ្យ«កាប់យួន»ក៏ដោយ គឺយួនជាអ្នកបញ្ជាពីក្រោយ ដើម្បីវាមានឱកាសមកវាយកំទេចបំផ្លិចបំផ្លាញស្រុកខ្មែរ) ។ តុក្កតាបញ្ចូលរូបរបស់យួនដូច្នេះ មិនអាចចាត់ទុកថាជាស្តេចខ្មែរបានទេ... គឺជាស្តេចយួន !!



សម្តេចសីហនុនិងអ្នកម្នាងម៉ូនិក ថតជាមួយទីប្រឹក្សាយួន
នៅលើផ្លូវលំហូ-ជីមិញ កាលពីឆ្នាំ១៩៧៣

ខ្ញុំមានភស្តុតាងច្រើនណាស់ ដែលបង្ហាញពីភក្តីភាពរបស់ឧត្តមសេនិយលន់-នល់ ចំពោះសម្តេចសីហនុ ។ នៅថ្ងៃទី១២មិនា១៩៧០, វេលារសៀល (គឺជាថ្ងៃបន្ទាប់ពីថ្ងៃបាតុកម្មវាយស្ថានទូតយៀកកុងនិងយៀកណាមខាងជើងនៅភ្នំពេញ) ខ្ញុំបានអានទូរលេខសម្ងាត់មួយដែលស្តេចសីហនុបានផ្ញើមកមាតាទ្រង់ (ហើយដែលលោកសឿ-ច័ន្ទសាធបានយកមកឲ្យខ្ញុំពីក្រសួងឃោសនាការជាតិ) ។ បន្ទាប់ពីអានអត្ថបទនោះកាលណាខ្ញុំមានលក្ខណៈដូចជាមនុស្សម្នាក់ដែលត្រូវព្រះធរណីស្រូប ពីព្រោះសម្តេចសីហនុបានថ្កោលទោសយ៉ាងធ្ងន់ធ្ងរទៅលើរដ្ឋាភិបាល, ទៅលើ

រដ្ឋសភា ជាពិសេសទៅលើពួកបាតុករ ដែលទ្រង់បានចាត់ទុកថា ជា«អ្នកស្នេហាជាតិដែលស្រេកឃ្លានប្រាក់ដុល្លារ»...



បាតុកម្មវាយស្ថានទូតយួនខាងជើងនៅក្រុងភ្នំពេញ

«...ខ្ញុំ(ស្ដេចសីហនុ) មិនអាចជឿទាល់តែសោះ ថាពួកគេមានហឹង្សានិយមហួសជន្លោលបែបនេះ ដែលជាការផ្ទុយស្រឡះពីផលប្រយោជន៍ខ្ពង់ខ្ពស់ និងកេរ្តិ៍ឈ្មោះដ៏ល្អនៃប្រទេសជាតិយើង (sis!) ។ ខ្ញុំដឹងច្បាស់ណាស់ថា ព្រឹត្តិការណ៍ដ៏ធ្ងន់ធ្ងរនេះ បានត្រូវបង្កើតឡើងដោយសារពួកវរជន ដែលមានគោលបំណងចង់បំផ្លិចបំផ្លាញមិត្តភាពរវាងកម្ពុជានិងពិភពសង្គមនិយម ហើយជំរុញប្រទេសយើងឲ្យធ្លាក់ចូលក្នុងកណ្ដាប់ដៃនៃមហាអំណាចចក្រពត្តិនិយម និងមូលធននិយម (sic!) » ។

ពេលឲ្យចំទៅ សម្ដេចសីហនុបានចោទលោកថា ជាអ្នកធ្វើអំពើហឹង្សាទៅលើជនជាតិយួន ដោយលក់ខ្លួនបំរើផលប្រយោជន៍អាមេរិកាំង ។



លោកឧត្ដមសេនិយ លន់-នល់

ប៉ុន្តែខ្ញុំបានដឹងច្បាស់ណាស់ថា «បាតុកម្មដេញយួន» គឺសម្ដេចជាអ្នកបញ្ជាឲ្យធ្វើ គឺតាំងពីចំនួនបីខែមុនកើតព្រឹត្តិការណ៍ ។ តាំងពីខែវិច្ឆិកា១៩៦៩ម្ល៉េះ, ខ្ញុំបានដឹងពីក្រុមសហការីរបស់ឧត្ដមសេនិយលន់-នល់ (ជាពិសេសពីលោកថោង-លឹមហួង)ថា «ថៅហ្វា-យ (ស្ដេចសីហនុ) ឲ្យលោកធំ ( លន់-នល់) រៀបចំធ្វើបាតុកម្មដេញយួន» ។ ចំណែកការដាក់ទូតចងស្ពានមេត្រីជាមួយអាមេរិកាំងឡើងវិញ ដើម្បីយកជំនួយ «ដុល្លារ» ក៏នៅតែសម្ដេចជាអ្នកធ្វើខ្លួនឯង ហើយលើកកំហុសនេះទៅដាក់លោកលន់-នល់ ថាជាជនក្បត់ទៅវិញ ។ គឺពីព្រោះដូចតែជនជាតិលាវឆ្កួតនៅខាងលើ ដែលណែនាំខ្មែរឲ្យកាប់យួន ដើម្បីឲ្យយួនលេបទឹកដី ស្ដេចសីហនុក៏ជាតុក្កតាបញ្ចូលរូបរបស់យួនដូចគ្នា ។ ស្ដេចសីហនុត្រូវយួនស្រូបយកព្រលឹងតាំងពីយូរយារណាស់មកហើយ ។

ខ្ញុំសូមធ្វើសារបានរឿងតាំងពីដើមឆ្នាំ១៩៦៩ឡើងវិញ ៖

★ ខែកុម្ភៈឆ្នាំ១៩៦៩ ៖ សម្ដេចសីហនុបានសរសេរអត្ថបទវិចារណកថាដោយខ្លួនឯង នៅក្នុងទស្សនាវដ្ដីរដ្ឋ Le Sangkum ដោយដាក់ចំណងជើងថា ៖ La curée (ការកាប់ក្បាលសត្វបោះឲ្យឆ្កែ ឬការចូលលុករាតត្បាត, បោសសំអាតប្លន់របអូស) ។ នៅក្នុងអត្ថបទនោះ សម្ដេចសីហនុ





បាតុកម្មនៅខាងមុខស្តូប«សាធារណរដ្ឋខ្មែរ» ឆ្នាំ១៩៧០

បានបញ្ជាក់ជាអាទិថា ៖ «នៅពេលណាដែលកងទ័ពអាមេរិកាំងចេញផុតពីឥណ្ឌូចិនអស់ទៅ កងទ័ពវៀតណាមខាងជើងនឹងចូលមករាតត្បាតបោសសំអាតនៅប្រទេសកម្ពុជាគ្មានសល់អ្វីឡើយ...» ។ នេះមិនគឺជាសញ្ញាញាក់ភ្នែករបស់ស្ដេច ឲ្យជនជាតិខ្មែរកាប់សម្លាប់យួន និងចូលអាមេរិកាំងទេឬ ?

★ ថ្ងៃ១៨មិនា១៩៦៩ ៖ គឺជាថ្ងៃដែលសម្ដេចសីហនុឲ្យសញ្ញាភ្លើងខៀវមកអាមេរិកាំង ដើម្បីទម្លាក់គ្រាប់បែកទៅលើយៀកកុងនៅតាមព្រំប្រទល់ (តាមពត៌មានដែលខ្ញុំបានទទួលពីគ្រប់ទិសទី, គ្រាប់បែកទាំងនេះច្រើនធ្លាក់ទៅលើប្រជាជនខ្មែរ, មិនសូវជាបានត្រូវទៅលើក្បាលយៀកកុងប៉ុន្មានទេ) ។ ទោះជាយ៉ាងណាក្ដី, ថ្ងៃ«១៨មិនា» ទាំង១៩៦៩ ទាំង១៩៧០ គឺជាថ្ងៃជ្រើសរើសរបស់សម្ដេចសីហនុ, មិនមែនរបស់លោកលន់នល់ទេ ។ ដោយស្ដេចជាតុក្កតារបស់យួន ថ្ងៃ១៨មិនានេះក៏ជាថ្ងៃជ្រើសរើសរបស់យួនដើម្បីពួកវាអាចប្លន់ទឹកដីកម្ពុជាបានដោយសេរីនោះដែរ ។

នៅថ្ងៃ១៨មិនា១៩៧០, នៅក្នុងយន្ដហោះសូវៀតមួយ ដែលដឹកនាំស្ដេចសីហនុពីទីក្រុងមូស្គូទៅប៉េកាំង, សម្ដេចព្រះប្រមុខរដ្ឋខ្មែរបានសំរេចបង្កើតរដ្ឋាភិបាលយៀកកុងមួយជាមួយសម្ដេចប៉ែន-នុត ហើយនិងអ្នកម្នាងម៉ូនិក ។ តទៅនេះគឺជាសំដីរបស់ទ្រង់ផ្ទាល់ទៅកាន់អ្នកម្នាង ៖

« ទេ ! ទេ ! (ខ្ញុំព្រះករុណា ខ្ញុំបានថ្លែង) នៅគ្រប់ពេលណាៗទាំងអស់ ពេលនេះពុំមែនជាពេលដែលយើងត្រូវលាក់ខ្លួនពួកអាត្មានោះទេ ពួក





<u>រូបខាងលើ</u> ៖ សម្តេចសីហនុ និងលោកប៉ែន-នុត កំពុងធ្វើសេចក្តីប្រកាសបង្កើត«រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា» (GR-UNK) នៅទីក្រុងប៉េកាំង, ខែឧសភាឆ្នាំ១៩៧០ ។
<u>រូបខាងក្រោម</u> ៖ សម្តេចសីហនុញញឹមពព្រាយកំពុងលើកបង្ហាញរដ្ឋធម្មនុញ្ញនៃរាជរដ្ឋាភិបាលថ្មី ។

យើងនឹងត្រូវថ្កោលទោសជាប្រវត្តិសាស្រ្ត ប្រសិនណាហើយបើយើងអនុញ្ញាត ឲ្យកម្ពុជាក្លាយទៅជាមិនត្រឹមតែជាអំណាចផ្តាច់ការឃោធាប៉ុណ្ណោះទេ តែទៅជាដីអាណានិគមសាជាថ្មីម្តងទៀត ។ ពេញមួយជីវិតរបស់ខ្ញុំៗតែងបានយលសប្តិស្រមើស្រមៃនឹងការប្រយុទ្ធតស៊ូ ដើម្បីឯករាជ្យរបស់ប្រទេសខ្ញុំ ។ ខ្ញុំពុំមែនជាអ្នកតណ្តើមឯករាជ្យពីបារាំងយកមកបោះបង់ចោលនៅពេលនេះទៅវិញទេ ។ រាជានិយមមិនត្រូវឈមឈរនៅក្រៅសៃវៀននោះឡើយ ។ ជាការច្បាស់ណាស់ ចក្រពត្តិនិយមអាមេរិកាំងនឹងត្រូវទទួលបរាជ័យបះជើងនៅឥណ្ឌូចិន ហើយយើងត្រូវតែចូលប្រឡូកក្នុងការប្រយុទ្ធតស៊ូនេះ ។ អាមេរិកាំងនឹងត្រូវទទួលបរាជ័យដោយពួកវៀតណាមនិងពួកខ្មែរក្រហមរបស់យើង ដែលរួបរួមគ្នាទាំងអស់ជាមួយនិងយើង ។ ចំណែកពួកប៉ាថេតឡាវ នឹងច្បាស់ជាបានជោគជ័យនៅប្រទេសលាវ ។ គឺជាករណិយកិច្ចរបស់រាជានិយម ដែលត្រូវនៅខាងប្រជារាស្រ្ត» ។

«ម៉ូនិកស្រាប់តែយល់ពាក្យសំដីរបស់ខ្ញុំមួយរំពេជ ។ យើងអង្គុយធ្វើការនៅពីមុខតុមួយ, ម៉ូនិកនៅក្បែរខាងខ្ញុំ ចំណែកប៉ែន-នុតនៅចំពីមុខខ្ញុំ ។ នៅពេលដែលយន្តហោះរបស់យើង ហោះលើកំពស់១០,០០០ម៉ែត្រ នៅលើវាលលំហនៃ ស៊ីបេរីយ៉ា ខ្ញុំក៏ចាប់ផ្តើមព្រាងសេចក្តីថ្លែងការណ៍មួយ ដែលជាសេចក្តីអំពាវនាវឲ្យមានការតស៊ូ ( <u>កកន</u> ៖ សំរែកបិសាចដែលហៅប្រជារាស្រ្តខ្មែរ ឲ្យរត់ចូលព្រៃម៉ាគី ដើម្បីធ្វើសហប្រតិបត្តិការជាមួយយៀកកុង ), ជាឯកសារមួយមានតម្លៃប្រវត្តិសាស្រ្តស្មើនឹងសេចក្តីអំពាវនាវរបស់ឧត្តមសេនិយ ដឺគ្គោល នៅថ្ងៃ១៨មិថុនា ដែលហៅប្រជារាស្រ្តបារាំង ឲ្យងើបឈរឡើងប្រយុទ្ធតស៊ូនឹងពួកឈ្លានពានណាស៊ី ។ ខ្ញុំនៅចាំបានថា គ្មាននរណាម្នាក់បាននិទ្រាទេក្នុងការធ្វើដំណើរនេះ ។ ពួកយើងស្ថិតនៅក្នុងស្ថានភាពរំភើបញាប់ញ័រច្របូកច្របល់ ដែលមិនអនុញ្ញាតឲ្យនិទ្រាបាន ។ នៅពេលដែលម៉ូនិក, សម្តេចប៉ែន-នុត ហើយនិងខ្លួនខ្ញុំធ្វើការមិនឈប់ឈរដើម្បីបញ្ចប់សេចក្តីថ្លែងការណ៍នេះ ដែលនឹងត្រូវផ្សាយតាមវិទ្យុ (ប៉េកាំង) នៅថ្ងៃទី២៣មិនា...» (ដកស្រង់ចេញពី «My war with the CIA» by Norodom Sihanouk - p. 28) ។

យោងតាមអត្ថបទខាងលើនេះ ខ្ញុំបានសង្កេតឃើញថា នៅថ្ងៃទី១៨មិនា១៩៧០ សម្តេចសីហនុត្រេកអរសប្បាយខ្លាំងណាស់ ទាល់តែដេកមិនលក់ ក្នុងប្រការបានក្លាយខ្លួនទៅជាស្តេចយៀកកុង ។ សម្តេចសីហនុមានសេចក្តីរំភើបញាប់ញ័រ ដោយបានសំរេចគំរោងការណ៍មួយ ដែលគាត់មានការប៉ុនប៉ងប្រាថ្នាពីយូរមកហើយ គឺក្លាយទៅជាស្តេចក្រហម ។ ដូច្នេះគំរោងការណ៍ «ទម្លាក់ស្តេច» នៅថ្ងៃទី១៨មិនា១៩៧០នេះ ជាគំរោងការណ៍របស់គាត់ មិនមែនជារបស់ឧត្តមសេនិយលន់-នល់ទេ គឺជាល្បែងថ្លិនភ្នែកមួយ ដែលអនុញ្ញាតឲ្យគាត់រត់ទៅធ្វើស្តេចយៀកកុង ។

យើងវិលត្រឡប់មកថ្ងៃទី១៨មិនា១៩៧០ឡើងវិញ ។ ស្តេចសីហនុខ្លួនឯងជាអ្នកញុះញង់ និងជាអ្នកឲ្យភ្លើងខៀវទៅលោក Henry Kissinger ដើម្បីទម្លាក់គ្រាប់បែកទៅលើទឹកដីនៃប្រទេសកម្ពុជា នៅក្នុងកិច្ចប្រតិបត្តិការសំងាត់នៃរដ្ឋការនិចសុន (ក្រោមការទើសទាល់របស់លោកប្រធានាធិបតីនិចសុន លោក Melvin Laird រដ្ឋមន្ត្រីការពារប្រទេស និងក្រោមការប្រឆាំងរបស់លោក William Rogers រដ្ឋមន្ត្រីការបរទេស ។ «Operation Breakfast commenced on March 18 (1969). The following day Kissinger was, according to Haldeman, «beaming» as early reports showed that the compaign was a success. In the fourteen nonths following the commencement of the bombing in March 1969, the United States conducted 3,630 B-52 bombing raids in Cambodia territory » (Excerpt from «The Flawed Architect, Henry Kissinger and American Foreign Policy» by Jussi Hanhimäki, Oxford University Press 2004 - p. 44-45) ។

ទាំងអស់នេះជាភស្តុតាងមួយប៉ុនភ្នំ ដែលបង្ហាញអំពីសេចក្តីស្មោះត្រង់ របស់ឧត្តមសេនិយលន់-នល់, ពោលគឺលោកពុំបានស៊ុំគ្រលុំជាមួយអាមេរិកាំង ដើម្បីពង្រីកសង្គ្រាមចូលក្នុងទឹកដីកម្ពុជានោះទេ <u>តែគឺសម្តេចសីហនុជាអ្នកធ្វើខ្លួនឯង</u> ។ គួរជ្រាបថា នៅសម័យថ្ងៃទី១៨មិនា១៩៦៩... វាសនានៃប្រទេសកម្ពុជាបានត្រូវក្តោបក្តាប់ដោយសម្តេចវាំងបីរូប ដែលសុទ្ធសឹងតែជាទ្រើង-មិញយ៉ាង បង្កប់ខ្លួនក្នុងព្រះរាជវាំងខ្មែរ ៖

★ <u>សម្តេចបវរសេដ្ឋាមហាសម្បត្តិ សឺន-សាន</u> ៖ ជារដ្ឋមន្ត្រីក្រសួងការបរទេស និងជាស្ថាបត្យករនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចកុម្មុយនិស្តនៅក្នុងសង្គមរាស្រ្តនិយមរបស់ស្តេចសីហនុ ។ សម្តេចសឺន-សាន បានណែនាំឲ្យសីហនុកាត់ទូតជាមួយនឹងអាមេរិកាំង នៅពេលដែលអាមេរិកាំងនៅពេញកម្លាំងផ្តល់ជំនួយ ហើយណែនាំឲ្យស្តេចសីហនុត្រូវរ៉ូវជាមួយអាមេរិកាំងឡើងវិញ នៅពេលដែលអាមេរិកាំងហាត់ធៀយ (ដកទ័ពចេញពីឥណ្ឌូចិន) ។ គឺសម្តេចសឺន-សាន (មិនមែនឧត្តមសេនិយលន់-នល់) ដែលបានចរចាដាក់ទូតជាមួយអាមេរិកាំងឡើងវិញ (ជាមួយលោក Chester Bowles) នៅភ្នំពេញ ខែមករា១៩៦៨ ដែលកាលនោះ លោកសឺន-សានមានឋានៈជារដ្ឋមន្ត្រីទី១ ។ ដូច្នេះ គឺសម្តេចសឺន-សានដែលបានណែនាំកម្ពុជាទៅរកបរាជ័យនៃផ្លូវការទូត ពោលឲ្យធ្លាក់ក្នុងភ្លើងសង្គ្រាម

អាមេរិកាំង-យួន ដោយលើកទោសកំហុសទម្លាក់ទៅលើឧត្តមសេនិយ
លន់-នល់ ។

★ <u>សម្ដេចចក្រី ញឹក-ជូឡុង</u> ៖ អគ្គបញ្ជាការកងទ័ពដែលបានបង្កើត
ព្រឹត្តិការណ៍សម្លាប់ខ្មែរក្រហមនៅសំឡូតយ៉ាងរង្គាល អស់ចំនួនបីពាន់
នាក់ ហើយទម្លាក់កំហុសទៅលើឧត្តមសេនិយលន់-នល់ដូចគ្នា។ សម្ដេ
ចទាំងពីរខាងលើនេះ បន្ទាប់ពីបានប្រព្រឹត្តឧក្រិដ្ឋកម្មរួចហើយ ក៏បានរត់
ទៅពួនសម្ងំនៅប្រទេសបារាំង (១៩៦៩) ដើម្បីរង់ចាំមើលប្រទេសកម្ពុ-
ជារមៀលធ្លាក់ទៅក្នុងជ្រោះមហន្តរាយ ។

★ <u>សម្ដេចស្រីស្រីង្គារចៅហ្វាវាំង ប៉ែន-នុត</u> ៖ ជារដ្ឋមន្ត្រីទី១របស់
សម្ដេចសីហនុ នៅថ្ងៃទី១៨មិនា១៩៦៩ នៅភ្នំពេញ ហើយក៏ជារដ្ឋមន្ត្រី
ទី១របស់ស្ដេចសីហនុដដែល នៅថ្ងៃទី១៨មិនា១៩៧០ នៅក្រុងប៉េកាំង។
រដ្ឋាភិបាលប៉ែន-នុតនៅភ្នំពេញ ជារដ្ឋាភិបាលដែលបានសម្លាប់ពួកខ្មែរ
ក្រហមយ៉ាងព្រៃផ្សៃ តែប្រែក្លាយទៅជារដ្ឋាភិបាលខ្មែរក្រហមទៅវិញ
នៅក្រុងប៉េកាំង ដែលមានភារកិច្ចលើកទ័ពយួនមកវាយប្រហារឧត្តម-
សេនិយលន់-នល់ និងក្រុមនិស្សិតបាតុករនៅភ្នំពេញ អំពីបទឧក្រិដ្ឋពីរ
យ៉ាងដែលពួកគេបានប្រព្រឹត្ត ៖ គឺអំពើក្បត់ជាតិចូលអាមេរិកាំង (ទម្លាក់
ស្ដេច) និងការសម្លាប់យួន ។ គឺដូចជាពិធីយកបាយស្វាទៅលាបមាត់ព-
ពែរដូច្នោះ មុននឹងបង្កើតសង្គ្រាមប្រល័យពូជសាសន៍ខ្មែរ !

⌘

⌘ ⌘

<u>សញ្ញាឃើញទី២</u> ៖ ពិភពលោកទាំងមូល ហើយសូម្បីតែជនជាតិខ្មែរ
ខ្លួនឯងក៏បានឃើញថា លោកលន់-នល់សម្លាប់យួនដែរ ។ តាមសេចក្ដី
ពិតគឺយួនទៅវិញទេ (ពួកវៀតណាមកុម្មុយនិស្ត) ដែលបានបាញ់សម្លាប់
យួនគ្នាវា ចងស្លាបសេកយ៉ាងរង្គាល (គឺពួកវៀតណាមកាតូលិកចំនួន៥
ពាន់នាក់) ហើយយកទៅទម្លាក់យ៉ាងស្អេកស្កះខ្ទាន់ខ្ទាប់ក្នុងទឹកទន្លេមេ-
គង្គ រហូតដល់សាទ្បាងនៅអ្នកលឿងបើកបរឆ្លងកាត់ស្ទើរមិនរួច ជាហេ
តុបណ្ដាលឲ្យពិភពលោកទាំងមូលថ្កោលទោសរដ្ឋាភិបាលលន់-នល់ ថា
ជារដ្ឋាភិបាល «ឃាតករ» ។ ដូច្នេះយួនវាយប្រហារដល់ថ្លើមប្រមាត់នៃ
ប្រទេសកម្ពុជាទៅហើយ តែលោកមេទ័ពខ្មែរត្រូវគេចងដៃជាប់ គ្មានឲ្យ
ធ្វើអ្វីកើតឡើយ ។

នៅក្នុងព្រឹត្តិការណ៍ច្របូកច្របល់នៃ «ថ្ងៃ១៨មិនា១៩៧០» ពួកបាតុ
ករនៅភ្នំពេញ មានការភ័យបារម្ភថាសម្ដេចសីហនុយាងមកវិញ មកផ្ដន្ទា
ទោសពួកខ្លួន ។ ម្លោះហើយពួកគេស្រមើស្រមៃឃើញឧត្តមសេនិយល
ន់-នល់ជាមនុស្សខ្លាំង ដើម្បីទប់ទល់នឹងស្ដេចឆ្កួតលីលា ។ ដល់គេឃើ
ញយួនស្លាប់អណ្ដែតទឹក គេក៏ជឿថាលោកលន់-នល់ជាមនុស្សខ្លាំងប-
ណ្ដោយទៅ ពោលគឺជា«ឃាតករ»សម្លាប់យួន ។ ចំណែកលោកឧត្តម
សេនិយលន់-នល់វិញនឹកស្មានតែពួកបាតុករ ហើយនិងកូនទាហានរប
ស់លោកជ្រុលដៃជ្រុលជើង ពិព្រោះព្រឹត្តិការណ៍«កាប់យួន»នេះ បាន
កើតឡើងបន្ទាប់ពីបាតុកម្មប្រឆាំងនឹងវត្តមានយៀកកុងនៅលើទឹកដីកម្ពុ
ជា (ដោយប្រការវាយស្ថានទូតយៀកកុងនៅភ្នំពេញ) ។ ក៏ប៉ុន្តែ ខ្ញុំមាន
ភស្តុតាងច្រើនណាស់ដែលបង្ហាញថា ការកាប់សម្លាប់យួនទាំងនេះ ពុំ
មែនខ្មែរជាអ្នកធ្វើទេ ៖

ទី១- នៅថ្ងៃទី២០មិនា១៩៧០, (បន្ទាប់ពីការដកតំណែងព្រះប្រមុខ
រដ្ឋតាមផ្លូវច្បាប់ ដោយពួកក្រុមអ្នកតំណាងរាស្ត្រ) ខ្ញុំបានចូលទៅក្នុងផ្ទះ
ឧត្តមសេនិយលន់-នល់នៅទំនប់ទឹក ។ នៅទីលានក្រោយគេហស្ថាន
មានទាំងរោងសេនាធិការបណ្ដោះអាសន្នមួយ ។ នៅពេលនោះ ពួកក្រុម
មេទាហានបានយកបញ្ជាមួយរបស់លោកឧត្តមសេនិយ មកឲ្យខ្ញុំអាន (
ជាភាសាបារាំង) « **Ordre à toutes les unités combattantes de ne
pas faire la répression par les armes**»(«បញ្ជាទៅដល់កងទ័ពប្រយុ
ទ្ធទាំងអស់ មិនឲ្យធ្វើសង្គ្រាមដោយគ្រឿងអាវុធ») ។ ដូច្នេះលោកលន់-
នល់មិនបានបញ្ជាឲ្យសម្លាប់នរណាទាំងអស់ ទោះយួនក្ដី ខ្មែរក្ដី...

ទី២- សូមអានឯកសារមួយរបស់បារាំង, របស់លោក **Jean Mori-
ce** ៖ «វាមានលំនាំហាក់ដូចជាថា នៅពេលដែលកំហឹងប្រជារាស្ត្រខ្មែរ
កើតឡើងហើយ មានពួកភ្នាក់ងារយៀកកុង ដែលបានឆ្លៀតឱកាស-
នឹងព្រឹត្តិការណ៍នេះ ដើម្បីបង្វិលកំហឹងមហាជន ឲ្យផ្ដោតទៅលើពួកវៀត
ណាមកាតូលិក ដែលមិនព្រមបណ្ដោយខ្លួនឲ្យលង់ទៅក្នុងការឃោសនា
របស់ពួកកុម្មុយនិស្ត...

«ចំណែកការដឹកនាំផ្តល់ស្បៀង (ទៅឲ្យយៀកកុង) ដែលធ្វើឡើង
ដោយជួរឡានកាមីញ៉ុងជាច្រើន ដែលចាកចេញពីកំពង់ផែភ្នំពេញ និង
ជួរឡានកាមីញ៉ុងដទៃទៀត ដែលដឹកភស្តុភារដូចគ្នាពីក្រុងកំពង់សោមក៏
ត្រូវបានផ្អាកបញ្ឈប់ ។ ជាលទ្ធផល, ពួកកងទ័ពកុម្មុយនិស្តវៀតណាម
ក៏ចាប់ផ្ដើមសំរុកចូលមកដែនដីខាងក្នុង ព្រមទាំងធ្វើការរឹបជាន់ដល់ប្រ
ជាជនខ្មែរ ដែលពួកគេបំភិតបំភ័យគំរាមកំហែងដោយចុងអាវុធ ។ រូប
ថតជាច្រើនដែលបោះពុម្ពផ្សាយដោយអង្គការពត៌មានផ្សេងៗ បានបង្ហា
ញពីក្បាលខ្មែរ ដែលគេកាត់ដោតនៅលើចំរឹងឫស្សី...

«ម៉្យាងវិញទៀត ពួកភ្នាក់ងារវិទ្ធង្សនាកុម្មុយនិស្ត (ខ្មែរយៀកមិញ)
ក៏បានរត់ចូលមកប្រសេចប្រសាច ចូលមកក្នុងដែនដីខាងក្នុងប្រទេស
ផងដែរ ក្នុងប្រការបំផុសបំផុល ឲ្យមានការបះបោរប្រឆាំងនឹងរដ្ឋាភិបាល
លន់-នល់ ។ កាលពីថ្ងៃទី១១និង១២មិនា១៩៧០, ពួកភ្នាក់ងារយៀកមិញ
នេះបានជំរុញឲ្យមានការពិឃាតរង្គាល ទៅលើចំណោមប្រជាជនយួនកា
តូលិក ដែលមិនមែនជាកុម្មុយនិស្តនៅកម្ពុជា ក្នុងប្រការធ្វើសម្ពាធន៍ឲ្យ
ពួកនេះចូលក្នុងជួរកងទ័ពយៀកកុង ហើយឆ្លៀតឱកាសនោះ បង្ខូច
ឈ្មោះរដ្ឋាភិបាលនៅភ្នំពេញ...» **(Cambodge, du sourire à l'horreur
- p.206)** ។

⌘

⌘ ⌘

គេបានចោទឧត្តមសេនិយលន់-នល់ថា ជាអ្នកបង្កើតសង្គ្រាមនៅ
ស្រុកខ្មែរ (ដោយទម្លាក់ស្ដេច) ។ ដើម្បីធ្វើសង្គ្រាមនៅកម្ពុជា គេត្រូវមាន
កត្តាពីរយ៉ាងដែលលោកលន់-នល់គ្មាន ៖ គឺកត្តាចាំបាច់ (**Condition né
cessaire**) និងកត្តាគ្រប់គ្រាន់ (**Condition suffisante**) ។ កត្តាទាំងពីរ
នេះ គឺឋិតនៅក្នុងកណ្ដាប់ដៃផាំ-យ៉ាំងដុងឯណោះទេ ៖

<u>កត្តាចាំបាច់</u> ៖ ផាំ-យ៉ាំងដុងមានកងទ័ព២០ម៉ឺននាក់នៅព្រំប្រទល់ក
ម្ពុជា ប្រដាប់ដោយគ្រឿងអាវុធស្រោចតាំងពីក្បាលដល់ជើង...

<u>កត្តាគ្រប់គ្រាន់</u> ៖ ផាំ-យ៉ាំងដុងមានស្ដេចខ្មែរឆ្កួតម្នាក់ ឈ្មោះនរោ
ត្តម-សីហនុ, ដែលចង់បំរើបដិវត្តន៍យៀកមិញ ដោយស្នងរាជ្យពីហូ-ជី
មិញ ។ ដោយដុតកម្ពុជាឲ្យទៅជាផេះផង់ និងឲ្យធ្លាក់ទៅក្នុងសហព័ន្ធកុម្មុ
យនិស្តឥណ្ឌូចិន... ស្ដេចសីហនុមានសង្ឃឹមថា នឹងបានធ្វើ «ស្ដេចសតូ
ចស្ដើងសោយរាជ្យនគរបី» ព្រមទាំងអាចតណ្ហើមរាជ្យបល្ល័ង្កខ្មែរ យក
មកថ្វាយសង្សារថ្លើមប្រមាត់ស្រីយួនយៀកកុង **Monique Izzy** ។ ព្រោះ
ពេលដែលសីហនុរត់ចោលស្រុក នៅថ្ងៃទី៦មករា១៩៧០, សីហនុមិនបា
នខឹងនឹងឧត្តមសេនិយលន់-នល់ទេ តែខឹងនឹងម្ដាយខ្លួនឯងដែលបាន
ហាមឃាត់ខ្លួន មិនឲ្យឡើងគ្រងរាជ្យជាមួយនឹងអ្នកម្នាងម៉ូនិក ។

«កូនបានសន្យាដល់ប្រជានុរាស្ត្រថា មិនវិលត្រឡប់មករាជបល្ល័ង្កវិញទេ ។ បើកូនចង់ឡើងគ្រងរាជ្យវិញនាពេលនេះ វាទាល់តែកូនដើរជាន់លើខ្មោចម៉ែ»...

នេះជាសំដីដែលមហាក្សត្រីយានីកុសុមៈបានថ្លែងទៅកាន់ស្តេចសីហនុ នៅមុនថ្ងៃ១៨មិនា១៩៧០ ។

ហើយប្រវត្តិសាស្ត្រក៏បានបង្ហាញឲ្យឃើញថា សម្តេច«បានដើរជាន់លើខ្មោចម៉ែពិតមែន»... ជាន់លើខ្មោចម៉ែមែនទែនផង ព្រមទាំងជាន់ទៅលើខ្មោចមាតា-មាតុភូមិរបស់ខ្លួនទៀតផង ។៚